**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**<u>ព័ត៌មានពិស្តារអំពីការដាក់ឯកសារ</u>**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៣

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 26-Mar-2013, 15:06
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**សំណើសុំរបស់ក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ឲ្យមានការដាក់បញ្ចូលឯកសារថ្មីមួយនៅក្នុងកិច្ចពិភាក្សាដេញដោល**

---

| | |
|---|---|
| | <u>ដាក់ជូន</u>៖ |
| <u>ដាក់ដោយ</u>៖ | **អង្គជំនុំជម្រះសាលាដំបូង៖** |
| **មេធាវីការពារក្ដីលោក ខៀវ សំផន** | ចៅក្រម និល ណុន |
| មេធាវី គង់ សំអុន | ចៅក្រម Silvia CARTWRIGHT |
| មេធាវី Anta GUISSÉ | ចៅក្រម យូរ ឧត្ដារា |
| មេធាវី Arthur VERCKEN | ចៅក្រម Jean-Marc LAVERGNE |
| មេធាវី Jacques VERGÈS | ចៅក្រម យ៉ា សុខន |

**ជំនួយការ៖**
លោកស្រី សេង សុជាតា
កញ្ញា Marie CAPOTORTO
កញ្ញា Shéhérazade BOUARFA
កញ្ញា Mathilde CHIFFERT
កញ្ញា អ៊ុច ស្រីផាត់
កញ្ញា សុគន្ធ ម៉ូនិកា
លោក Pierre TOUCHE
កញ្ញា Blandine ZELLER

**សហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោក Andrew CAYLEY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្តីទាំងអស់**

## សូមគោរពជូនអង្គជំនុំជម្រះសាលាដំបូង

១. កាលពីថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១៣ ក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន បានដឹងអំពីបទសម្ភាស ដែលផ្ដល់ដោយសាក្សីអ្នកជំនាញលោក Philip SHORT ទៅកាន់សារព័ត៌មានភ្នំពេញប៉ុស្ដិ៍ (Phnom Penh Post) ក្នុងថ្ងៃជាមួយគ្នានោះ[1]។

២. បច្ចុប្បន្ននេះ ផ្អែកលើវិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុង ក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន បានស្នើសុំឱ្យដាក់បញ្ចូលឯកសារនេះទៅក្នុងកិច្ចពិភាក្សាដេញដោល និងចាត់ទុកឯកសារនេះថាជាឯកសារភ័ស្ដុតាង[2]។

៣. វាមិនអាចប្រកែកបានទេដែលថាកិច្ចសម្ភាសនេះដែលបានធ្វើ និងផ្សព្វផ្សាយកាលពីខែ មីនា ឆ្នាំ ២០១៣ មិនមាននៅក្នុងសំណុំរឿង មុនពេលដែលមានការបើកការជំនុំជម្រះក្ដីនោះ។ ក្រុមមេធាវីការពារក្ដីមិនអាចរកឯកសារនៃកិច្ចសម្ភាសនោះបានឡើយ មុនពេលដែលមានការចុះផ្សាយអំពីកិច្ចសម្ភាសនោះ បើទោះបីជាខ្លួនបានខិតខំប្រឹងប្រែងរកអស់ពីសមត្ថភាពក៏ដោយ...

៤. ក្រៅពីនេះ ឯកសារថ្មីនេះមានសារៈសំខាន់ដល់ការបង្ហាញការពិត និងបំពេញបន្ថែមដល់លក្ខណៈវិនិច្ឆ័យដែលមានចែងនៅក្នុងវាក្យខណ្ឌ ៣ នៃវិធាន ៨៧[3]។

---

[1] អត្ថបទសារព័ត៌មានភ្នំពេញ ប៉ុស្ដិ៍ មានចំណងជើងថា « *Pol Pot biographer talks tribunal* » បទសម្ភាសន៍របស់ Justine DRENNAN ជាមួយ Philip SHORT នៅថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១៣ មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ។

[2] "ក្នុងកំឡុងពេលសវនាការ តាមគំនិតផ្ដួចផ្ដើមរបស់អង្គជំនុំជម្រះ ឬតាមការស្នើសុំរបស់ភាគី អង្គជំនុំជម្រះអាចកោះហៅ ឬស្ដាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬទទួលយកនូវភស្ដុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត។ គ្រប់ភាគីដែលបានស្នើសុំត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឱ្យបានច្បាស់លាស់។ អង្គជំនុំជម្រះនឹងធ្វើសេចក្ដីសម្រេចចំពោះការស្នើសុំនោះ ផ្អែកតាមខ្លឹមសារដែលមានចែងនៅក្នុងវិធាន ៨៧(៣) ខាងលើ។ ភាគីដែលស្នើសុំត្រូវតែធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថាសក្ខីកម្ម ឬភស្ដុតាងដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលការចាប់ផ្ដើមជំនុំជម្រះ"។

៥. ជាក់ស្តែង នៅក្នុងអំឡុងនៃកិច្ចសម្ភាសនោះ លោក Philip SHORT បានដំណាលអំពីការជួបសន្ទនាគ្នាអស់រយៈពេលដ៏យូរវាងលោក និងលោក ខៀវ សំផន កាលពី ១២ ឆ្នាំ មុន។ គាត់បានបញ្ជាក់ថា ពួកគាត់ទាំងពីរនាក់បានសន្ទនាគ្នាអំពីបញ្ហាជាក់ស្តែងនានាដែលពាក់ព័ន្ធនឹងរឿងក្តីនាពេលបច្ចុប្បន្ននេះ។

៦. លោក Philip SHORT ក៏បានលើកឡើងផងដែរអំពីកិច្ចសម្ភាសនានាដែលលោកបានធ្វើជាមួយសាក្សីជាច្រើននាក់ ដែលសាក្សីទាំងនោះបានចូលខ្លួនមកផ្តល់សក្ខីកម្មដល់អង្គជំនុំជម្រះរួចហើយ។ គាត់បានលើកឧទាហរណ៍អំពីសាក្សីមួយរូបដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ហើយដែលខ្លឹមសារនៃសក្ខីកម្មនោះ មានលក្ខណៈខុសគ្នាទៅនឹងសក្ខីកម្មដែលគាត់បានផ្តល់ដល់លោក Philip SHORT ហើយអ្នកជំនាញបានអះអាងថា គាត់បានថតយកសម្លេងនៃការផ្តល់សក្ខីកម្មនោះផងដែរ។

៧. ម្យ៉ាងវិញទៀត អត្ថបទសារព័ត៌មាននោះមានលក្ខណៈសមហេតុសមផល ដោយហេតុថាលោក Philip SHORT បានលើកឡើងនៅក្នុងអត្ថបទនោះ អំពី៖

- អង្គហេតុដែលជាប់ពាក់ព័ន្ធនឹងសៀវភៅរបស់លោក ដែលបានដាក់ចូលក្នុងកិច្ចពិភាក្សារួចហើយ[4] ហើយ ដែលបានពិពណ៌នាអំពីគោលគំនិត និងសកម្មភាពរបស់ពួកខ្មែរក្រហម។

- អត្ថបទមួយដែលលោកបានសរសេរកាលពីពេលមុន[5] ហើយដែលអង្គជំនុំជម្រះធ្លាប់បានចាត់ទុកអត្ថបទនោះថាមានសារៈសំខាន់ដល់ការបង្ហាញការពិត និងបានសម្រេចដាក់បញ្ចូលក្នុងកិច្ចពិភាក្សា[6]។

---

[3] "(...) អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធចំពោះពាក្យសុំឲ្យពិនិត្យភស្តុតាង បើយល់ឃើញថា៖ ក- មិនជាប់ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នា, ខ- មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ, គ- មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុ ដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង, ឃ- ច្បាប់មិនអនុញ្ញាត ឬ ង- មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍។"

[4] Pol Pot, Anatomie d'un cauchemar និពន្ធដោយ Philip SHORT ឯកសារ **E3/9**។

[5] ការតស៊ូមតិរបស់ក្រុមបីសាច៖ មិនគួរមានតុលាការកាត់ទោសខ្មែរក្រហម និពន្ធដោយ Philip SHORT *ភ្នំពេញ ប៉ុស្តិ៍* ច្បាប់ចេញផ្សាយ ៩/២៣ ថ្ងៃទី ១០ ដល់ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០០ ឯកសារ **E226/1.1.1**។

[6] អនុស្សរណៈស្តីពី ចម្លើយតបទៅនឹងសំណើតាមវិធាន ៨៧(៤) សុំដាក់ឯកសារថ្មីទៅក្នុងសំណុំរឿង ពាក់ព័ន្ធនឹងសក្ខីកម្មរបស់សាក្សីលោក François PONCHAUD និងលោក Sydney SCHANBERG (E243) ព្រមទាំងអ្នកជំនាញលោក Philip SHORT

៨. ដោយឡែក មេធាវីការពារក្តីលោក ខៀវ សំផន បានបញ្ជាក់នៅទីនេះថា មេធាវីការពារក្តីបានស្នើសុំការបកប្រែឯកសារដ៏ខ្លីមួយនេះ ដែលនឹងត្រូវបកប្រែជាបីភាសាការងាររបស់ អ.វ.ត.ក មុនពេលដែលមានការចូលមកផ្តល់សក្ខីកម្មពីសំណាក់លោក Philip SHORT។

៩. ហេតុដូច្នេះហើយ មេធាវីការពារក្តីលោក ខៀវ សំផន សូមស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូងមេត្តាដាក់បញ្ចូលឯកសារថ្មីមួយនេះទៅក្នុងកិច្ចពិភាក្សាដេញដោល និងចាត់ទុកឯកសារនេះថាជាឯកសារភ័ស្តុតាងក្នុងសំណុំរឿង។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br>មេធាវី Anta GUISSÉ<br>មេធាវី Arthur VERCKEN<br>មេធាវី Jacques VERGÈS | ភ្នំពេញ<br>ប៉ារីស<br>ប៉ារីស<br>ប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |

(E226, E226/1 និង E230) និងលោកស្រី Elizabeth BECKER (E232 និង E232/1) ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ ឯកសារ **E260** កថាខណ្ឌ ៤ និង ៦។